# តួនាទីនៃការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា[១]

## ១. សេចក្តីផ្តើម

ចាប់ពីដើមទសវត្សរ៍១៩៩០ មក ប្រទេសកម្ពុជាបានផ្លាស់ប្តូរពីសេដ្ឋកិច្ចផែនការ ទៅជាសេដ្ឋកិច្ចទីផ្សារ និងពីភាពឯកោ ទៅធ្វើសមាហរណកម្មជាមួយប្រទេសនានាក្នុងតំបន់ និងសកលលោក។ ក្នុងអំឡុងជិតបីទសវត្សរ៍កន្លងមក រចនាសម្ព័ន្ធសេដ្ឋកិច្ចបានផ្លាស់ប្តូរជាបណ្តើរៗពីសេដ្ឋកិច្ចពឹងផ្អែកលើកសិកម្ម ទៅជាសេដ្ឋកិច្ចពឹងផ្អែកលើឧស្សាហកម្ម និងសេវាកម្មវិញ។ ការផ្លាស់ប្តូរនេះ គួបផ្សំនឹងចរន្តសមាហរណកម្មកាន់តែខ្លាំងក្នុងអាស៊ាន បានបង្កើតនូវបញ្ហាប្រឈមថ្មីៗ ដល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក៏ដូចជា គ្រឹះស្ថានឧត្តមសិក្សាក្នុងការផ្លាស់ប្តូរ និងពង្រីកការបណ្តុះបណ្តាលរបស់ខ្លួន ដើម្បីធានាឲ្យសេដ្ឋកិច្ចមានលក្ខណៈប្រកួតប្រជែងទាំងក្នុងតំបន់ និងសកលលោក។ ប្រទេសកម្ពុជាបាន និងកំពុងធ្វើឲ្យសម្បូរបែប និងពង្រឹងបន្ថែមនូវ មូលដ្ឋានគ្រឹះកម្រិតទាបសព្វថ្ងៃនៃធនធានមនុស្ស ដើម្បីលើកកម្ពស់ប្រភពថ្មីៗមានចីរភាពល្អនៃកំណើនសេដ្ឋកិច្ច និងកែលំអជីវភាពរស់នៅរបស់ប្រជាជន។ យុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សនេះ មានដាក់បញ្ចូលនៅក្នុងគ្រប់ផែនការអភិវឌ្ឍជាតិ ដូចជាផែនការកាត់បន្ថយភាពក្រីក្រ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

របាយការណ៍សំយោគនេះ ពិភាក្សាពីការផ្លាស់ប្តូរក្នុងសេដ្ឋកិច្ចកម្ពុជា ដោយពិនិត្យទៅលើតម្រូវការកម្លាំងពលកម្ម និងបែបបទដែល គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងគ្រឹះស្ថានឧត្តមសិក្សា អាចចូលរួមចំណែកជំរុញការផ្លាស់ប្តូរទាំងនេះ ជាពិសេសពិនិត្យពីជំនាញនានា ដែលមានតម្រូវការសម្រាប់កំណើនសេដ្ឋកិច្ច។

## ២. ការប្រែប្រួលក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច និងផលប៉ះពាល់ទៅលើតម្រូវការជំនាញ

តាំងពីឆ្នាំ២០០០ មក សេដ្ឋកិច្ចកម្ពុជាមានកំណើនប្រចាំឆ្នាំជាមធ្យមជាង ៨% (World Bank 2012)។ ផសស ពិតបានកើន ៦,៩% ក្នុងឆ្នាំ២០១១, កើន ៦,៦% ក្នុងឆ្នាំ២០១២ និងរំពឹងថាកើន ៦,៧% ក្នុងឆ្នាំ២០១៣។ តាមការព្យាករណ៍ ប្រទេសកម្ពុជានឹងមានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ប្រមាណ ៧% ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ (Huot 2013)។ ដោយឡែក វិស័យកសិកម្មបានកើន ៣% ក្នុងឆ្នាំ២០១១ និង ៤,៥% ក្នុងឆ្នាំ២០១២ ប៉ុន្តែវិស័យឧស្សាហកម្ម និងសេវាកម្មបានថយចុះកំណើនពី ៨,៦% ក្នុងឆ្នាំ២០១១ មកត្រឹម ៧,២% ក្នុងឆ្នាំ២០១២ (Tong & Madhur 2013)។

មកទល់បច្ចុប្បន្ន វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម មានចំណែកយ៉ាងសំខាន់ក្នុងកំណើនសេដ្ឋកិច្ច។ ចំណែកនៃវិស័យឧស្សាហកម្ម ក្នុង ផសស បានកើនពី ២២,៤% នៅឆ្នាំ២០០៨ ដល់ ២៦,៤% នៅឆ្នាំ២០១០ (ក្នុងនេះ វិស័យកាត់ដេរ និងវាយនភ័ណ្ឌមាន ១២%) ហើយចំណែកនៃវិស័យសេវាកម្មបានកើនពី៣៨,៨%ដល់៤០,៦%(ក្នុងនេះសណ្ឋាគារ និងភោជនីយដ្ឋានបានរួមចំណែក ៤,៤%) (NIS 2008; Hing *et al.* 2012)។ ផ្ទុយទៅវិញ ចំណែកនៃវិស័យកសិកម្មបានធ្លាក់ចុះពី ៣៨,៨% នៅឆ្នាំ២០០៨ មកត្រឹម ៣៣% នៅឆ្នាំ២០១០។ តាមនេះ វិស័យឧស្សាហកម្ម និងសេវាកម្មបានផ្តល់ការងារឲ្យពលករ បានច្រើនជាងវិស័យកសិកម្ម។ ជាក់ស្តែង ពលករក្នុងវិស័យឧស្សាហកម្មបានកើនពី ៨,៥% នៃចំនួនពលករសរុបក្នុងឆ្នាំ២០០៨ ដល់ ១២% ក្នុងឆ្នាំ២០១០ ហើយពលករក្នុងវិស័យសេវាកម្មបានកើនពី ១៩,២% ដល់ ២០% ប៉ុន្តែពលករក្នុងវិស័យកសិកម្មបានថយចុះពី ៧៣,២% មកត្រឹម ៦៨% ក្នុងរយៈពេលដូចគ្នា។

ថ្វីបើសេដ្ឋកិច្ចកម្ពុជា កំពុងរីកចម្រើនទៅខាងឧស្សាហកម្ម និងសេវាកម្មក្តី ប៉ុន្តែវិស័យទាំងនេះនៅតូចនៅឡើយ ហើយប្រើប្រាស់ពលករបានតែមួយភាគតូចប៉ុណ្ណោះ។ ម្យ៉ាងទៀត វិស័យឧស្សាហកម្មមានមូលដ្ឋានតូចចង្អៀត និងគ្របដណ្តប់ដោយសកម្មភាពកាត់ដេរដែលប្រើបច្ចេកវិទ្យាកម្រិតទាប ប៉ុន្តែស្រូបយកបានរហូតដល់ ៨០% នៃកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្ម។ គេឃើញមានដែរនូវ កំណើនវិនិយោគក្នុងសកម្មភាពផលិតកម្មផ្តល់តម្លៃបន្ថែមខ្ពស់ (ដូចជា គ្រឿងបន្លាស់យានយន្តនិងគ្រឿងអេឡិចត្រូនិក)ពីសំណាក់ក្រុមហ៊ុនជប៉ុននិងកូរ៉េខាងត្បូង (Carteret 2013) ។ វិស័យសេវាកម្មមានកំណើនជាសំខាន់ដោយសារអាជីវកម្មផ្សេងៗ ពាក់ព័ន្ធនឹងទេសចរណ៍។ ចំពោះវិស័យកសិកម្មវិញ ទោះបីចំណែករបស់វាបានថយចុះក្នុង ផសស និងកម្លាំងពលកម្មសរុបក្តី ប៉ុន្តែក៏នៅតែជាប្រភពដ៏សំខាន់មួយនៃកំណើនសេដ្ឋកិច្ច និងការងារសម្រាប់ពលករ។

រចនាសម្ព័ន្ធសេដ្ឋកិច្ចបែបនេះ បង្ហាញពីតម្រូវការទាបនូវកម្លាំងពលកម្មមានជំនាញ ជាពិសេសជំនាញកម្រិតខ្ពស់ ប៉ុន្តែ

---

[១] អត្ថបទនេះរៀបរៀងឡើងដោយ **បណ្ឌិត អ៊ុន លាង** និង **បណ្ឌិត ជួន រម្យរាសី** ជាអ្នកសម្របសម្រួលក្រុមស្រាវជ្រាវផ្នែកអប់រំ និង **បណ្ឌិត ផិន ច័ន្ទរិទ្ធ** ជាសមាជិកគណៈកម្មាធិការដឹកនាំការងារនៃវេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា។ របាយការណ៍នេះផ្អែកលើសិក្ខាសាលាស្រាវជ្រាវឆ្នាំ២០១២-២០១៣, ការពិភាក្សាគោលនយោបាយតុមូល, និងសម័យប្រជុំនានា ដែលរៀបចំដោយក្រុមស្រាវជ្រាវផ្នែកអប់រំ សម្របសម្រួលដោយ **សាកលវិទ្យាល័យភូមិន្ទភ្នំពេញ** (RUPP) ជាដៃគូមួយក្នុងវេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា។

ក៏មានតម្រូវការនូវជំនាញប្រភេទខ្លះ សម្រាប់ការកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ផលិតភាព និងអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពដែរ។ ក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ ដែលកសិកម្មនៅមានទំហំធំជាងគេ (ជាពិសេស ប្រជាជនភាគច្រើនដែលធ្វើការងារក្នុងវិស័យកសិកម្ម មានកម្រិតជីវភាពត្រឹមមួយចិញ្ចឹមពោះ) ហើយវិស័យឧស្សាហកម្មក៏នៅក្មេងខ្ចី ប៉ុន្តែមានការអនុវត្តបែបថ្មីផ្នែកបច្ចេកវិទ្យា និងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងដំណើរការអភិវឌ្ឍនោះ ជំនាញដែលមានតម្រូវការខ្លាំងបំផុត រួមមាន ជំនាញកម្រិតមធ្យមផ្សេងៗខាងបច្ចេកទេសនិងវិជ្ជាជីវៈ និងជំនាញកម្រិតខ្ពស់មួយចំនួនតូចខាងវិទ្យាសាស្ត្រ វិស្វកម្ម ផលិតកម្ម សំណង់ និងបច្ចេកវិទ្យា ជាដាង ជំនាញខាងវិទ្យាសាស្ត្រសង្គម ពាណិជ្ជកម្ម និងការគ្រប់គ្រង (Un 2012)។

ថ្វីបើប្រជាជនកម្ពុជានៅក្មេងជាង ប្រជាជនប្រទេសអាស៊ានឯទៀតក្តី ប៉ុន្តែនៅមានផលិតភាពទាបជាងគេ។ ជាក់ស្តែងនៅឆ្នាំ២០១០ ប្រជាជនកម្ពុជា ៦៤,៣០% មានអាយុពី ១៥ ទៅ ៦៤ឆ្នាំ (UNPD 2011, cited in Heng 2013) ប៉ុន្តែផលិតកម្មរបស់ប្រជាជនក្នុងវ័យធ្វើការ មានត្រឹម ៣.៤០០ដុល្លារអាមេរិក ធៀបនឹង ១០.៤០០ ដុល្លារអាមេរិកជាមធ្យម សម្រាប់អាស៊ាន (APO 2011, cited in Heng 2013)។ តួលេខនេះមានន័យថា កម្ពុជាត្រូវកែលំអផលិតភាពកម្លាំងពលកម្ម ដើម្បីពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ខ្លួននៅក្នុងតំបន់។

## ៣. តួនាទីនៃ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច

### ៣.១. ជំនួយគាំទ្រដល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៅទសវត្សរ៍ ១៩៩០

នៅដើមទសវត្សរ៍១៩៩០ ការសិក្សាពីតួនាទីវិស័យអប់រំក្នុងការអភិវឌ្ឍប្រទេសកម្ពុជា បានធ្វើសេចក្តីសន្និដ្ឋានស្រដៀងគ្នាថា គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដែលផ្តល់នូវនិស្សិតបញ្ចប់ការសិក្សាបានតែ ២០០០នាក់/ឆ្នាំនោះ មិនអាចបំពេញតម្រូវការកម្លាំងពលកម្មជំនាញ និងបំពេញកិច្ចការស្តារ និងកសាងប្រទេសដែលទទួលរងការបំផ្លិចបំផ្លាញបានឡើយ (ADB 1997)។ ការវាយតម្លៃរបស់ដៃគូអភិវឌ្ឍនានាលើការវិនិយោគ និងការអភិវឌ្ឍនៅថ្ងៃអនាគតនៅកម្ពុជា ក៏បានអះអាងដែរថា ការពង្រឹងសេដ្ឋកិច្ចជាតិអាចសម្រេចបានលឿនតាមការធ្វើវិនិយោគទៅលើវិស័យអប់រំ និងបណ្តុះបណ្តាល ដែលផ្តល់ផ្លែផ្កាភ្លាមៗ (Duggan 1997)។ ការអះអាងនេះបាននាំឲ្យមានការផ្តល់អាទិភាពទៅលើ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជាជាង គ្រឹះស្ថានអប់រំថ្នាក់ឧត្តមសិក្សា ដោយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ជាពិសេសអង្គការពលកម្មអន្តរជាតិ(ILO) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA)។

ដោយមានជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍នានា រដ្ឋាភិបាលបានបង្កើតក្រុមការងារ ដើម្បីកសាងកម្មវិធីសិក្សា និងយុទ្ធសាស្ត្រថ្មីៗ សំដៅធ្វើឲ្យការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ កាន់តែបានប្រសើរឡើង។ បន្ទាប់មក ក្រុមប្រឹក្សាបណ្តុះបណ្តាលថ្នាក់ជាតិ ដែលមានសមាជិកជាមន្ត្រីរដ្ឋាភិបាល គ្រូបណ្តុះបណ្តាល និងនិយោជក ត្រូវបានបង្កើតឡើងក្រោមការដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំគោលនយោបាយជំរុញឲ្យការបណ្តុះបណ្តាល និងការអប់រំ បានស្របទៅតាមតម្រូវការទីផ្សារការងារ។ ម្យ៉ាងទៀត ក៏មានការបែងចែកនូវមូលនិធិបណ្តុះបណ្តាលថ្នាក់ជាតិមួយ សម្រាប់ពង្រីកដែនគ្របដណ្តប់នៃ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដែរ។ ជាលទ្ធផល មជ្ឈមណ្ឌលបច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏កើតមានឡើងនៅគ្រប់ខេត្តទាំងអស់។

ដៃគូអភិវឌ្ឍន៍នានា ក៏បានជួយទ្រទ្រង់ដល់អង្គការមិនមែនរដ្ឋាភិបាលទាំងក្នុងស្រុក និងអន្តរជាតិជាច្រើន ដើម្បីឲ្យផ្តល់នូវកម្មវិធីបណ្តុះបណ្តាលផ្សេងៗ ដែលអាចបត់បែនតាមកាលៈទេសៈ និងឆ្លើយតបបានលឿនទៅនឹងតម្រូវការរបស់អ្នកទទួលផលជាច្រើនក្រុម។ ក្នុងអំឡុងពេលនោះ គ្រឹះស្ថានផ្តល់សេវាអប់រំឯកជនបានកើនចំនួនឡើង ជាពិសេសសម្រាប់ការបណ្តុះបណ្តាល ភាសាអង់គ្លេស និងជំនាញកុំព្យូទ័រ ដែលឆ្លុះបញ្ចាំងពីការផ្តល់អាទិភាពដល់វគ្គបណ្តុះបណ្តាលខ្លីៗ ជាជាង ការបង្កើតនូវប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាផ្លូវការ។

ជំនួយឧបត្ថម្ភដល់ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈក្នុងអំឡុងពេលនេះ មានលក្ខណៈចំពោះកិច្ច (មិនអចិន្ត្រៃយ៍) ដាច់ដោយដុំ និងផ្តោតជាសំខាន់ទៅលើតម្រូវការបន្ទាន់ ដោយមិនបានគិតគូរដល់ការរៀបចំជាលក្ខណៈប្រព័ន្ធនូវគោលនយោបាយ និងផែនការសម្រាប់តម្រូវការពលកម្មជំនាញក្នុងរយៈពេលវែង ការធានាគុណភាព ឬយន្តការសម្របសម្រួលជំនួយនោះទេ។ ក្នុងបរិបទនេះ រដ្ឋាភិបាលបានស្នើឲ្យពួកដៃគូអភិវឌ្ឍន៍ជួយបង្កើត ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈគ្រប់ជ្រុងជ្រោយមួយ ដើម្បីដោះស្រាយបញ្ហាសំខាន់ពីរ។ បញ្ហាទី១ គឺការលុបចោលការធានាការងារក្នុងវិស័យសាធារណៈ ហើយក្នុងនេះត្រូវធ្វើវិភាគទីផ្សារការងារយ៉ាងល្អិតល្អន់សំដៅដោះស្រាយនូវតម្រូវការពលកម្មជំនាញ។ បញ្ហាទី២ ត្រូវបង្កើតទីភ្នាក់ងារសម្របសម្រួលមួយ ពីព្រោះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈផ្សេងៗ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងខុសៗគ្នា (ADB 1997)។

ថ្វីបើកំណែទម្រង់នេះ នាំឲ្យមានកំណើននិស្សិតចុះឈ្មោះចូលរៀន (ប្រហែល១០.០០០នាក់) ក្តី ប៉ុន្តែកំណើននេះមានកម្រិតទាបណាស់ ហើយមុខជំនាញយកមកបង្រៀនក៏មានតិចមិនអាចឆ្លើយតបទៅនឹងទីផ្សារការងារបានទេ (ADB 2004)។ កង្វះជំនាញនេះធ្វើឲ្យមានមុខតំណែងនៅទំនេរ ច្រើនជាងអ្នកស្វែងរកការងារធ្វើ។ យោងតាមព័ត៌មានពីទីភ្នាក់ងារជាតិស្វែងរកការងារ នៅកម្ពុជាក្នុងឆ្នាំ២០១០-១២ មានការងារនៅទំនេរ ៣៥.៩៧៦កន្លែង ប៉ុន្តែមានអ្នកដាក់ពាក្យសុំការងារតែ ៦៨៦០ នាក់ប៉ុណ្ណោះ (១៩,០៦%) (NEA 2012, cited in Heng 2013)។កង្វះព័ត៌មានទីផ្សារការងារនិងសេចក្តីណែនាំអំពីអាជីព ឬក៏ផែនការក្នុងចំណោមយុវជន ក៏អាចបង្កភាពមិនស៊ីគ្នារវាងការងារ និងអ្នកដាក់ពាក្យសុំការងារ ធ្វើដែរ (Hay 2012) ។

## ៣.២. ឧបសគ្គក្នុងការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

កង្វះខាតហិរញ្ញវត្ថុ ភាពដាច់ដោយដុំ[២] និងសមត្ថភាពបុគ្គលិកនៅមានកម្រិត គឺជាឧបសគ្គចម្បងដល់ការពង្រីកដែនគ្របដណ្តប់នៃ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ម៉្យាងទៀត ក៏គួរពិចារណាទៅលើកត្តាផ្សេងៗជាច្រើនដែរ។ កត្តាទី១ ការប្រមូលផ្តុំគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៅតាមទីប្រជុំជន និងកង្វះលទ្ធភាពទទួលបានឥណទាននិងព័ត៌មានទីផ្សារ បានរារាំងគ្រឹះស្ថានអប់រំឯកជនក្នុងការពង្រីកដែនគ្របដណ្តប់របស់ខ្លួន (ADB 1997)។

កត្តាទី២ គឺលក្ខខណ្ឌនៃការបញ្ចប់ការអប់រំថ្នាក់មូលដ្ឋាន (៩ឆ្នាំ) ទើបអាចសិក្សានៅស្ថាប័នអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាផ្លូវការ បានកាត់បន្ថយការចុះឈ្មោះចូលរៀន ពីព្រោះសិស្សជាច្រើនបានបោះបង់ការសិក្សាមុនពេលបញ្ចប់កម្រិតមូលដ្ឋាន។ កត្តាទី៣ រដ្ឋាភិបាលមិនទាន់មានលទ្ធភាពបង្កើតគោលនយោបាយនិងយន្តការគាំទ្រ និងលើកកម្ពស់សមភាពរវាងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាមួយនឹង គ្រឹះស្ថានឧត្តមសិក្សា ដោយផ្តោតសំខាន់ទៅលើការបន្សុីគ្នារវាងឧស្សាហនីយកម្ម និងការអភិវឌ្ឍពលកម្មជំនាញ (Barber & Cheng 2010) នោះទេ។ ប្រព័ន្ធអប់រំមិនបានដាក់ឲ្យការបណ្តុះបណ្តាលវិជ្ជាជីវៈ មានអាទិភាពខ្ពស់ជាង ការបណ្តុះបណ្តាលជាន់ខ្ពស់ទេ ហើយតាមនេះក៏មិនបានជួយឲ្យជំនាញមានលក្ខណៈកាន់តែស៊ីគ្នាទៅនឹងទីផ្សារការងារនិងឲ្យការផ្គត់ផ្គង់កម្លាំងពលកម្មជំនាញ អាចបម្រើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ដើម្បីឈានឡើងដល់ដំណាក់កាលបន្ទាប់នៃឧស្សាហាភាវូបនីយកម្មនោះដែរ (Green 2009)។ នៅឆ្នាំ២០១២ ប្រទេសកម្ពុជាមាននិស្សិតថ្នាក់មហាវិទ្យាល័យប្រមាណជា ២៥០.០០០នាក់ (MoEYS 2012, cited in Heng 2013)។ ពួកយុវវ័យក៏ចូលចិត្តចុះឈ្មោះចូលរៀនថ្នាក់ឧត្តមសិក្សា ជាជាង ថ្នាក់អប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដែរ ទោះបី ទីផ្សារការងារត្រូវការច្រើនជាងនូវ ពលករមានជំនាញក្តី។ ពីឆ្នាំ២០០៨ ដល់ ២០១០ ប្រហែល ៨៧% នៃការងារដែលត្រូវបង្កើតក្នុងគម្រោងវិនិយោគទទួលបានការអនុម័តពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺជាការងារសម្រាប់ពលករប្រើកម្លាំងដែលមានជំនាញ ឬគ្មានជំនាញ (CDC 2011, cited in Heng 2013)។មានតែវិស័យសេវាកម្មទេដែលត្រូវការបុគ្គលិកមួយចំនួនតូចមានជំនាញផ្នែកគណនេយ្យ គ្រប់គ្រង ច្បាប់ ឬ សេដ្ឋកិច្ច។

កង្វះការចូលរួមពីអ្នកផ្តល់សេវាបណ្តុះបណ្តាលក្នុងការបង្កើតគោលនយោបាយ ជាកត្តាមួយទៀតនាំឲ្យ អ្នកវិនិយោគកាន់តែពុំសូវមានឆន្ទៈធ្វើវិនិយោគលើ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (Knight & MacLeon 2004)។ ការពិគ្រោះយោបល់មានធ្វើឡើងភាគច្រើនបំផុត តែរវាងមន្ត្រីរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល (MoEYS & Education Sector Working Group 2005)។

## ៣.៣. ការវិនិយោគសកម្មឡើងវិញលើការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

តាំងពីក្រសួងការងារ បណ្តុះបណ្តាល និងវិជ្ជាជីវៈ បានកកើតឡើងក្នុងឆ្នាំ២០០៥ មានធនធានកាន់តែច្រើនបានដាក់វិនិយោគទៅលើការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ជាក់ស្តែង ថវិការបស់រដ្ឋាភិបាលសម្រាប់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកើនពី ៧៥០.០០០ដុល្លារអាមេរិកក្នុងឆ្នាំ២០០៦ ដល់ ១៣,៣៤លានដុល្លារអាមេរិកក្នុងឆ្នាំ២០១២ ក្នុងនោះមានប្រហែល ៦៥% សម្រាប់ផ្តល់ទៅឲ្យវិទ្យាស្ថានបណ្តុះបណ្តាលនានា (ADB 2008a; Chan 2008)។ ម៉្យាងទៀត មានការសម្របសម្រួលកាន់តែប្រសើរឡើងជាមួយអ្នកផ្តល់សេវាអប់រំឯកជន ដើម្បីបង្កើតឲ្យមានកម្មវិធី និងវិទ្យាស្ថានអប់រំ កាន់តែច្រើនមុខច្រើនប្រភេទ។

ធនាគារអភិវឌ្ឍន៍អាស៊ីបានបង្កើនជំនួយឧបត្ថម្ភដល់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពី ១០លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៥ ដល់ ២៥លានដុល្លារអាមេរិកក្នុងឆ្នាំ២០១០ សម្រាប់អនុវត្តគម្រោងសាកល្បងលើការពង្រឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ រដ្ឋាភិបាលក៏បានប្តេជ្ញាជួយពង្រឹងគម្រោងនេះដែរ ដោយបានផ្តល់ថវិកាប្រមាណ ១០០លានដុល្លារអាមេរិក។ នៅឆ្នាំ២០០៣ ប្រទេសកូរ៉េខាងត្បូងបានផ្តល់ថវិកា ៥០លានដុល្លារអាមេរិក ដើម្បីបង្កើតមហាវិទ្យាល័យពហុបច្ចេកទេសជាតិដែលមានកម្មវិធីសិក្សាទាន់សម័យនិងបំពាក់ឧបករណ៍ទំនើបៗ (ADB 2008b)។

ជាលទ្ធផល ការចុះឈ្មោះចូលរៀនរបស់សិស្សបានកើនពីប្រហែល ១០.០០០នាក់នៅចុងទសវត្សរ៍១៩៩០ ដល់ ៩០.០០០នាក់នៅឆ្នាំ២០០៧ (ADB 2008b)។ ទោះបីចំនួនសិស្សចុះឈ្មោះចូលរៀនមានត្រឹម ១,១០% នៃកម្លាំងពលកម្មក្តី ប៉ុន្តែចំនួននេះវាស្មើនឹង ៣០% នៃកម្លាំងពលកម្មចំណូលថ្មីទៅក្នុងទីផ្សារការងារ និងជាសញ្ញាណវិជ្ជមានមួយ។ ក្នុងឆ្នាំ២០១០ នៅកម្ពុជាមានសិស្ស ១១៤.១៣៨នាក់ ដែលសិក្សាក្នុងវគ្គអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈរយៈពេលខ្លី (MoLVT 2011, cited in Heng 2013) ក្នុងនេះមាន ៦៤,៣០% បានចូលសិក្សាខាងកសិកម្ម និងត្រឹម ៨% ប៉ុណ្ណោះបានចូលសិក្សាខាងជំនាញបច្ចេកទេស។

កន្លងមកមានការផ្តួចផ្តើមគំនិតជាច្រើនហើយ ដើម្បីផ្លាស់ប្តូរទស្សនៈរបស់យុវវ័យ និងឪពុកម្តាយទៅលើការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ សិស្សដែលបានបញ្ចប់វគ្គអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តែងទទួលបានប្រាក់បៀវត្សរ៍ច្រើនជាងបុគ្គលិកការិយាល័យ និងមន្ត្រីរដ្ឋាភិបាលកម្រិតមធ្យម។ ហើយរវាងសិស្សបានបញ្ចប់វគ្គអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នឹងនិស្សិតបានបញ្ចប់ថ្នាក់ឧត្តមសិក្សា ក៏មិនមានគម្លាតប្រាក់បៀវត្សរ៍អ្វីច្រើនដែរ (NIS 2010)។ សិស្សដែលបានសិក្សាក្នុងវគ្គអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៅតាមស្ថានប័នមានការទទួលស្គាល់ជាផ្លូវការ តែងរកកម្រៃបានច្រើនជាងនិស្សិតបញ្ចប់ថ្នាក់ឧត្តមសិក្សា (D'Amico

---

[២] ឧទាហរណ៍ នៅពេល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកកើតឡើងក្នុងឆ្នាំ២០០៥ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់អនុវត្តកម្មវិធីសិក្សាថ្មីមួយ សម្រាប់ថ្នាក់មធ្យមសិក្សា ដែលក្នុងនោះមាន ជំនាញវិជ្ជាជីវៈសម្រាប់ជ្រើសយកនៅថ្នាក់ទី១១ និង ទី១២។ នាពេលថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ។

2012)។ ម្យ៉ាងទៀត សិស្សបានបញ្ចប់វគ្គអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក៏មានតួនាទីអាជីពច្រើនជាងនិស្សិតបញ្ចប់ថ្នាក់ឧត្តមសិក្សាដែរ (CSES 2009, cited in World Bank 2011)។

ទន្ទឹមគ្នានេះ នៅកម្ពុជាមានវគ្គអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរយៈពេលខ្លី (ពីបីខែ ដល់មួយឆ្នាំ) កាន់តែច្រើនឡើង ដែលបានបង្កើនសមត្ថភាពធ្វើការបណ្តុះបណ្តាល។ ការចុះឈ្មោះចូលរៀនក្នុងវគ្គបណ្តុះបណ្តាលខ្លីៗ មានចំនួនច្រើនជាងការចុះឈ្មោះចូលរៀនក្នុង វគ្គសិក្សាថ្នាក់សញ្ញាប័ត្ររងដែលមានរយៈពេលពីរឆ្នាំ (D'Amico, 2009)។ ការផ្លាស់ប្តូរនេះវាស្របទៅនឹងរចនាសម្ព័ន្ធសេដ្ឋកិច្ចដែលក្នុងនោះការងារមានប្រាក់កម្រៃជាផ្លូវការ នៅមានតិចនៅឡើយបើគិតជាភាគរយ ហើយវិស័យកសិកម្មនៅតែជួយស្រូបយក កម្លាំងពលកម្មភាគច្រើន។ រចនាសម្ព័ន្ធសេដ្ឋកិច្ចបែបនេះត្រូវការនូវ ជំនាញកម្រិតទាបដែលវគ្គសិក្សាខ្លីៗអាចផ្តល់ឲ្យបាន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនទាន់បានព្យាយាមក្តោបក្តាប់លើ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទាំងអស់ ដែលកំពុងស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងផ្សេងៗនោះទេ ហើយសព្វថ្ងៃគ្រាន់តែបានពង្រឹងតួនាទីរបស់ខ្លួនក្នុងការសម្របសម្រួលប៉ុណ្ណោះ (Pich 2008)។ ជំហរបែបនេះ ជួយឲ្យគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈមិនត្រឹមតែអាចដំណើរការបានជាធម្មតាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចរីកលូតលាស់ល្អប្រសើរឡើងទៀតផង។

## ៤. តួនាទីឧត្តមសិក្សាក្នុងការអភិវឌ្ឍសេដ្ឋកិច្ច

### ៤.១. ជំនួយដល់គ្រឹះស្ថានឧត្តមសិក្សាក្នុងទសវត្សរ៍១៩៩០

នៅដើមទសវត្សរ៍១៩៩០ ឧត្តមសិក្សាមានការវិនិយោគមិនគ្រប់គ្រាន់ទេ ដោយទទួលបានត្រឹម ២% នៃថវិកាសាធារណៈសរុបដែលបែងចែកទៅឲ្យការអប់រំប៉ុណ្ណោះ។ ក្នុងអំឡុងទសវត្សរ៍១៩៩០ ឧត្តមសិក្សាគឺផ្តល់តាមគ្រឹះស្ថានសាធារណៈ ដោយមានការគ្របដណ្តប់កម្រិតទាប។ ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលផ្តល់អាហារូបករណ៍បានប្រហែល ២០០០កន្លែង ហើយតួលេខក្នុងពេលថ្មីៗនេះកើនដល់៤០០០កន្លែង។

នៅដើមទសវត្សរ៍១៩៩០ ឧត្តមសិក្សាបានអភិវឌ្ឍឡើងជាសំខាន់តាមរយៈជំនួយឧបត្ថម្ភពីខាងក្រៅ ជាពិសេសជំនួយទ្វេភាគី ដែលផ្តោតទៅលើ ការពង្រីកការបណ្តុះបណ្តាលភាសាបរទេស (បារាំង និងអង់គ្លេស) និងការស្រាវជ្រាវអំពីកំណែទម្រង់ការអប់រំ (Denham 1997; Sloper 1999)។

នៅចុងទសវត្សរ៍១៩៩០ ឯកជននីយកម្មបានចាប់ផ្តើមឡើងដើម្បីឆ្លើយតបទៅនឹង កំណើនចំនួនសិស្សបញ្ចប់ថ្នាក់មធ្យមសិក្សា។ ចាប់ពីពេលនោះមក ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានកើនឡើងយ៉ាងខ្លាំងពីត្រឹម ១៨ ក្នុងឆ្នាំ១៩៩៧ រហូតដល់ ៩៧ ក្នុងឆ្នាំ២០១១ (Mak 2012) ហើយចំនួនសិស្សចុះឈ្មោះចូលរៀនបានកើនឡើងពីប្រហែល ១០.០០០នាក់នៅដើមទសវត្សរ៍១៩៩០ ដល់ជាង ២២០.០០០នាក់នៅឆ្នាំ២០១១។

### ៤.២. ឧបសគ្គក្នុងការអភិវឌ្ឍការអប់រំថ្នាក់ឧត្តមសិក្សា

ទោះបីគ្រឹះស្ថានឧត្តមសិក្សាកើនចំនួនក្តី ប៉ុន្តែមិនទាន់បំពេញបានតាមតម្រូវការទីផ្សារពលកម្មទេ។ និស្សិតបញ្ចប់ថ្នាក់ឧត្តមសិក្សាជាច្រើននាក់គ្មានការងារធ្វើ ឬមានការងារធ្វើមិនពេញលេញ។ ជាក់ស្តែងក្នុងឆ្នាំ២០០៨ មានតែ ១០% នៃនិស្សិតបញ្ចប់ថ្នាក់ឧត្តមសិក្សាប៉ុណ្ណោះដែលមានការងារធ្វើ (CAMFEBA 2008) ហើយគេព្យាករណ៍ថា នៅឆ្នាំ២០១២ តម្រូវការទីផ្សារពលកម្មនូវនិស្សិតបញ្ចប់ថ្នាក់ឧត្តមសិក្សាមានត្រឹម ១៦.០០០នាក់ប៉ុណ្ណោះ សម្រាប់និស្សិត ២៩.០០០នាក់ ដែលគ្រឹះស្ថានឧត្តមសិក្សាបណ្តុះបណ្តាលបាន ហើយតួលេខនេះអាចមានត្រឹម ២២.០០០នាក់ សម្រាប់និស្សិតបញ្ចប់ឧត្តមសិក្សា ៧០.០០០នាក់ នៅឆ្នាំ២០១៤ (HRINC 2010, cited in D'Amico 2012)។ ដូចបានរៀបរាប់នៅខាងលើ ទីផ្សារពលកម្មត្រូវការអ្នកមានជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ។

បទដ្ឋានមិនល្អក្នុងការជ្រើសរើសនិស្សិតឲ្យចូលរៀន និងគុណភាពនៃការបណ្តុះបណ្តាល ជាកត្តាពីរដែលនាំឲ្យនិស្សិតបញ្ចប់ការសិក្សាមិនអាចរកការងារធ្វើបាន។ និយោជកត្រូវការបុគ្គលិក អ្នកគ្រប់គ្រង ឬអ្នកត្រួតពិនិត្យ ដែលមានជំនាញវិជ្ជាជីវៈខ្ពស់ (HRINC 2011, cited in D'Amico 2012)។ និយោជកច្រើនដល់ ៧៣% បញ្ជាក់ថា និស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យពុំមានជំនាញត្រឹមត្រូវទេ ហើយនិយោជក ៦២% ក៏បានវាយតម្លៃដូច្នេះដែរចំពោះ សិស្សបញ្ចប់វគ្គអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ តួលេខនេះ បង្ហាញពីការបង្រៀន កម្មវិធីសិក្សាមានគុណភាពអន់។ ទោះជានៅក្នុងជំនាញបច្ចេកវិទ្យាព័ត៌មាន[៣] ដែលមាននិស្សិតចុះឈ្មោះចូលរៀនតិចនាក់ក្តី ក៏មាននិស្សិតបញ្ចប់ការសិក្សាត្រឹម ៦២% ប៉ុណ្ណោះដែលរកការងារធ្វើបានក្នុងឆ្នាំ២០០៩ ហើយតួលេខនេះទំនងធ្លាក់ចុះដល់ ៣៣% ក្នុងឆ្នាំ២០១២ (CIST 2009)។ ប៉ុន្តែកម្ពុជានៅតែខ្វះខាត អ្នកបង្កើតកម្មវិធី និងអ្នករចនាក្រាហ្វិក។

និស្សិតបញ្ចប់ការសិក្សានៅខ្វះខាតជំនាញ ដើម្បីធ្វើការងារមានគុណភាពខ្ពស់ ឬការងារផ្តល់តម្លៃបន្ថែម ដែលមានស្រាប់ក្នុងប្រទេសកម្ពុជា កុំថាឡើយដល់ការងារបែបវិជ្ជាជីវៈដែលមានប្រាក់កម្រៃខ្ពស់។ ឧទាហរណ៍ ប្រមាណ ៥០% ការងារខាងបច្ចេកវិទ្យាព័ត៌មានជាប្រភេទការងារមាន"តម្លៃបន្ថែមទាប"(ឧទាហរណ៍ សេវាគាំទ្រផ្នែកបច្ចេកវិទ្យាព័ត៌មាន ប្រព័ន្ធព័ត៌មានវិទ្យា និងគ្រប់គ្រងបណ្តាញបញ្ជូនទិន្នន័យ) ដែលត្រូវការអ្នកជំនាញបច្ចេកទេស (សិស្សបញ្ចប់វគ្គអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ) (CIST 2009)។ ប៉ុន្តែក្នុងចំណោមអ្នកធ្វើការក្នុងផ្នែកនេះ ប្រហែលជាងពាក់កណ្តាលមានដល់សញ្ញាប័ត្រថ្នាក់បរិញ្ញា ឬថ្នាក់អនុបណ្ឌិត។ មួយវិញទៀត កម្លាំងពលកម្មក៏ត្រូវពង្រីកចំណេះដឹងលើផ្នែកភាសា និងជំនាញសង្គមដែរ (ដូចជា ជំនាញដោះស្រាយបញ្ហា ជំនាញទំនាក់ទំនង និងការគិតពិចារណាស៊ីជម្រៅ) (D'Amico, 2012)។

ការផ្គត់ផ្គង់ពលករជំនាញពីគ្រឹះស្ថានឧត្តមសិក្សា មានទំនោរគាំទ្រដល់សេវាកម្ម ច្រើនជាងខាង កសិកម្ម និងឧស្សាហកម្ម

[៣] ក្នុងឆ្នាំ២០១១ ប្រមាណ ៤% នៃនិស្សិតថ្នាក់ក្រោមឧត្តម បានចុះឈ្មោះសិក្សាបច្ចេកវិទ្យាព័ត៌មាន (Mak 2012)។

(Chet 2009)។ ពីឆ្នាំ២០០០ ដល់ ២០០៥ និស្សិតចុះឈ្មោះសិក្សាមុខវិជ្ជាបួនប្រភេទ (វិទ្យាសាស្ត្រ និងវិស្វកម្ម, ផលិតកម្មនិងសំណង់,សុខភាពនិងសុខុមាលភាព,និងកសិកម្ម) ដែលគេចាត់ទុកជាមុខវិជ្ជាស្នូល សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច មានត្រឹម ២៦.៦៤% ប៉ុណ្ណោះ។ ពីឆ្នាំ២០០១ ដល់ ២០០៤ ការចុះឈ្មោះចូលរៀនផ្នែកកសិកម្ម មានត្រឹម ៣,៣០-៣,៨០% ប៉ុណ្ណោះ ទោះបីជាវិស័យកសិកម្មផ្តល់ការងារច្រើនបំផុតដល់និស្សិតបញ្ចប់ការសិក្សាក្តី (Un 2012)។ ក្នុងឆ្នាំ២០១២ ប្រមាណ ៥០% នៃនិស្សិតថ្នាក់ឧត្តមសិក្សា កំពុងសិក្សាផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម (MoEYS 2012, cited in Heng 2013) និងមានតែ ៤% ប៉ុណ្ណោះដែលសិក្សាផ្នែកកសិកម្ម ហើយ ២,៥០% សិក្សាផ្នែកវិទ្យាសាស្ត្រ។

គ្រឹះស្ថានឧត្តមសិក្សាឯកជនភាគច្រើន ដំណើរការបណ្តុះបណ្តាលក្នុងទ្រង់ទ្រាយតូច ដោយសារដើមទុនមានកម្រិត ហើយត្រូវពឹងផ្អែកទាំងស្រុងលើ ការបង់ថ្លៃសិក្សារបស់សិស្ស។ កត្តានេះជំរុញឲ្យគ្រឹះស្ថានឯកជនទាំងនេះ ព្យាយាមទាក់ទាញសិស្សឲ្យចូលសិក្សាក្នុងគ្រឹះស្ថានរបស់ខ្លួន ជាជាងធ្វើការស្រាវជ្រាវ និងបង្រៀនជំនាញដែលសេដ្ឋកិច្ច ឬទីផ្សារពលកម្មត្រូវការ។ ម្យ៉ាងទៀត ប្រាក់ចំណូលមួយភាគធំបានចំណាយទៅលើផ្នែករដ្ឋបាល ដែលនាំឲ្យពួកគេមិនអាចធ្វើពិពិធកម្មកម្មវិធីសិក្សា ជាពិសេសទៅលើមុខវិជ្ជាវិទ្យាសាស្ត្រដែលមានតម្លៃខ្ពស់ និងត្រូវការវិនិយោគច្រើន។

ទាំងគ្រឹះស្ថានឧត្តមសិក្សា ទាំងក្រសួងអប់រំ យុវជន និងកីឡា ពុំទាន់មានចក្ខុវិស័យយូរអង្វែងទេ។ គ្រឹះស្ថានឧត្តមសិក្សាជាច្រើន ក៏គ្មានផែនការយុទ្ធសាស្ត្រដែរ។ គ្រឹះស្ថានឧត្តមសិក្សានានាស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង និងអាជ្ញាធរផ្សេងៗចំនួន ១៤ ដែលមានគោលនយោបាយដាច់ដោយឡែកពីគ្នា (Mak 2012)។ ដោយឡែក សេចក្តីព្រាងចក្ខុវិស័យឧត្តមសិក្សាឆ្នាំ ២០២០មិនបានទទួលការអនុម័តពីក្រសួងអប់រំយុវជននិងកីឡាទេ។ថ្មីៗនេះ សេចក្តីព្រាងចក្ខុវិស័យឧត្តមសិក្សាឆ្នាំ២០៣០ដែលមាន"ការឆ្លើយតបកាន់តែប្រសើរទៅនឹងបរិបទអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងតម្រូវការទីផ្សារ" ជិតទទួលបានការអនុម័តពីក្រសួងអប់រំ យុវជន និងកីឡា ហើយ (Mak 2012: 31)។

ក្រៅពីបញ្ហាដូចខាងលើ រដ្ឋាភិបាលនៅខ្វះខាតវិធានកែតម្រូវ។ Chet (2009) បានអះអាងថា សាកលវិទ្យាល័យសាធារណៈកំពុងប្រកួតប្រជែងជាមួយសាកលវិទ្យាល័យឯកជន ក្នុងផ្នែកវិទ្យាសាស្ត្រសង្គម ប៉ុន្តែមិនបានវិនិយោគទៅលើមុខវិជ្ជាវិទ្យាសាស្ត្រដែលគ្រឹះស្ថានឧត្តមសិក្សាឯកជននានា ពុំមានលទ្ធភាពបើកបង្រៀននោះទេ។ ទោះមានតម្រូវការច្រើនជាងនូវ អ្នកវិទ្យាសាស្ត្រ វិស្វករ អ្នកឯកទេស និងពលករជំនាញផ្នែកកសិកម្មក្តី ក៏រដ្ឋាភិបាលតែងផ្តល់អាហារូបករណ៍ក្នុងសមាមាត្រស្មើៗគ្នា ដល់និស្សិតផ្នែកវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។

ដៃគូអភិវឌ្ឍន៍ក៏មានចំណែកដែរ ក្នុងបញ្ហាចុះឈ្មោះចូលរៀនមិនបានគ្រប់គ្រាន់ក្នុងមុខវិជ្ជាមានអាទិភាពខ្ពស់។ ក្នុងជំនួយឧបត្ថម្ភរបស់ពួកគេសម្រាប់ខាងឧត្តមសិក្សា តាំងពីដើមទសវត្សរ៍១៩៩០ មក មានមួយភាគធំលើសលុបបានប្រើប្រាស់សម្រាប់មុខវិជ្ជាមិនជាប់ទាក់ទងនឹងវិទ្យាសាស្ត្រ។ ស្ថានភាពនេះវាផ្ទុយស្រឡះពីក្នុងទសវត្សរ៍១៩៨០ ដែលកាលនោះនិស្សិតកម្ពុជាភាគច្រើនបានសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រជាន់ខ្ពស់នៅតាមប្រទេសក្នុងប្លុកកុម្មុយនីស្ត។ មានតែប្រទេសម្ចាស់ជំនួយមួយចំនួនតូចប៉ុណ្ណោះ ដូចជា ជប៉ុន បារាំង និង កូរ៉េខាងត្បូង ជាដើម ដែលផ្តល់អាហារូបករណ៍សម្រាប់ មុខវិជ្ជាវិទ្យាសាស្ត្រជាន់ខ្ពស់ ប៉ុន្តែអាហារូបករណ៍ប្រភេទនេះ មានតិចតួចណាស់ (Barton 2008)។

## ៤.៣ ការវិនិយោគសកម្មឡើងលើឧត្តមសិក្សា

ទើបតែក្នុងពេលថ្មីៗនេះទេ ដែលរដ្ឋាភិបាលវិនិយោគច្រើនៗទៅលើឧត្តមសិក្សា ក្នុងនេះមានការផ្តល់មូលនិធិរួមចំណែក ៥០ % សម្រាប់ "គម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា" ជាមួយ ធនាគារពិភពលោក (Mak 2012)។ គម្រោងនេះមានគោលដៅពង្រឹងសមត្ថភាពគ្រប់គ្រង បង្រៀន និងស្រាវជ្រាវរបស់ គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន។ "អនុក្រុមការងារបច្ចេកទេសឧត្តមសិក្សា" ដែលមានការចូលរួមពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក៏ត្រូវបានបង្កើតឡើងដែរ។

ដើម្បីឆ្លើយតបនឹង កំណើនវិនិយោគក្នុងផ្នែកផលិតកម្មប្រើបច្ចេកវិទ្យាខ្ពស់ៗ (គ្រឿងបន្លាស់យានយន្ត និងសម្ភារៈអេឡិចត្រូនិក) រាជរដ្ឋាភិបាលបានប្តេជ្ញាបង្កើនជំនាញកម្លាំងពលកម្មតាមរយៈចំណាយបន្ថែម និងការសម្របសម្រួលលើគោលនយោបាយឧត្តមសិក្សា។ រាជរដ្ឋាភិបាលអាចបង្កើតជា "កន្លែងបណ្តុះបណ្តាលជំនាញឯកទេស" (សាកលវិទ្យាល័យបច្ចេកវិទ្យាខ្ពស់ៗ ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ) ដើម្បីបំពេញតម្រូវការនូវកម្លាំងពលកម្មមានជំនាញខ្ពស់ (Carteret 2013)។

## ៥. សេចក្តីសន្និដ្ឋាន និងការជាប់ទាក់ទងដល់គោលនយោបាយ

សេដ្ឋកិច្ចកម្ពុជាកំពុងបន្តរីកចម្រើនឡើង និងធ្វើពិពិធកម្មឆ្ពោះទៅខាងកម្មន្តសាលកម្ម។ ប៉ុន្តែ វិស័យកសិកម្ម និងសេវាកម្មនៅតែចូលរួមចំណែកយ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ច និងការបង្កើតការងារ។ ទោះបីកម្ពុជាមានចំណុចខ្លាំងដោយសារប្រជាជននៅក្មេង និងសកម្មខាងសេដ្ឋកិច្ចក្តី ក៏ផលិតភាពនៃកម្លាំងពលកម្មនៅមានកម្រិតទាប។ ដើម្បីឲ្យសេដ្ឋកិច្ចកាន់តែមានភាពប្រកួតប្រជែង ត្រូវមានការបន្សុីគ្នាកាន់តែល្អឡើងរវាងតម្រូវការពលកម្ម និងការផ្គត់ផ្គង់ធនធានមនុស្ស។ ទី១ គួរធ្វើការចងក្រង និងចែករំលែកទិន្នន័យលើទីផ្សារពលកម្មឲ្យបានកាន់តែប្រសើរឡើង ជាពិសេសក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានអប់រំបច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នៅពេលសិស្សបានទទួលព័ត៌មានប្រកបដោយគុណភាពស្តីពីចំណេះដឹង និងជំនាញដែលទីផ្សារពលកម្មត្រូវការ ពួកគេនឹងធ្វើការសម្រេចចិត្តដោយមានព័ត៌មានច្បាស់លាស់ ហើយជ្រើសរើសមុខវិជ្ជាសិក្សាបានយ៉ាងត្រឹមត្រូវ ជួយកាត់បន្ថយគម្លាតរវាងតម្រូវការ និងការផ្គត់ផ្គង់ធនធានមនុស្ស។ ទី២ កម្ពុជានៅមានកិច្ចការត្រូវធ្វើជាច្រើនទៀត ដើម្បីសម្របសម្រួលគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស និងធ្វើឲ្យគោលនយោបាយទាំងនេះកាន់តែឆ្លើយតបល្អនឹង យុទ្ធសាស្ត្រកំណើន/ឧស្សាហកាវូបនីយកម្ម។ ទី៣ កម្ពុជាត្រូវធ្វើវិនិយោគច្រើនថែមទៀតដើម្បីកែតម្រូវកម្មវិធីសិក្សាដែលមិនសមស្រប បង្កើនគុណភាពគ្រឹះស្ថានឧត្តមសិក្សា

និងគ្រឹះស្ថានអប់រំបច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន ពោលគឺ រវាងស្ថានប័នផ្តល់ការអប់រំបណ្តុះបណ្តាល នឹងនិយោជក។

អនាគតនៃសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកទៅលើ កម្លាំងពលកម្មវ័យក្មេងដែលអាចសម្របខ្លួន និងប្រកួតប្រជែងបានល្អទាំងក្នុងតំបន់និងលើសកលលោក។ ឥឡូវនេះដល់ពេលវេលាហើយដែលត្រូវធ្វើវិនិយោគឲ្យបានជិតដល់ ដើម្បីដោះស្រាយបញ្ហាប្រឈមមានអាទិភាពខ្ពស់នៃ ការលើកកម្ពស់សមត្ថភាពចូលបម្រើការងារ និងផលិតភាពកម្លាំងពលកម្ម៕

## ឯកសារយោង


ADB (1997), *Capacity building for TVET project, Cambodia*. TA 2516-CAM: Second interim report (Phnom Penh: ADB)

ADB (2004), *Report and recommendation of the president to the board of directors on proposed loans and technical assistance grant to the Kingdom of Cambodia for the second education sector development program*. RRP: CAM 34388 (Manila: ADB)

ADB (2008a), *Country operation business plan: Cambodia 2008-2010* (Phnom Penh: ADB)

ADB (2008b), *Kingdom of Cambodia: Preparing the strengthening technical and vocational education and training project*. Technical assistance report project number 40555 (Phnom Penh: ADB)

Barber, E. & S. Cheng (2010), "Plenty of jobs—But too few skilled workers", *Cambodia Daily*, 7-8 August 2010

Barton, C. (2008), "To the Soviet bloc and beyond", *Phnom Penh Post*, 13-26 June 2008

CAMFEBA (2008), *Youth and employment: Bridging the gap* (Phnom Penh: CAMFEBA)

Carteret, D. de (2013), "Manufacturing to diversify", *Phnom Penh Post*, 25 February 2013

Center for Information System Training (CIST) (2009), *Cambodia Professional IT Market Study* (Phnom Penh: CIST)

Chan, S. (2008), "Making the most of Cambodia's human resource", *Cambodia Development Review*, 12 (2), pp. 9-11.

Chet, C. (2009), "Higher education in Cambodia", in Y. Hirosato and Y. Kitamura (eds.), *The political economy of education reforms and capacity development in Southeast Asia: Cases of Cambodia, Laos and Vietnam* (New York: Springer Science and Business Media B.V.) pp. 153-165.

D'Amico, S. (2009), "Cambodia's human resource development: Building a skilled workforce", paper presented at Cambodia Outlook Conference, 12 March 2009, Phnom Penh

D'Amico, S. (2012), "Knowledge and skills needed by the Cambodian economy", presentation at policy roundtable on Higher Education and Vocational Training in Cambodia, 30 August 2012, Phnom Penh

Denham, P.A. (1997), *Higher education in Cambodia: Perspective of an Australian aid project* (Canberra: University of Canberra)

Duggan, S.J. (1997), "The role of international organizations in financing of higher education in Cambodia", *Higher Education*, 34 (1), pp. 1-22.

Green, N. (2009), "Coordinating Cambodia's recovery plan", *Phnom Penh Post*, 15 May 2009

Hay, H. (2012), "Key priorities for youth development and employment", presentation at policy roundtable on Higher Education and Vocational Training in Cambodia, 30 August 2012, Phnom Penh

Heng, S. (2013), "The role of TVET in economic development in Cambodia" (in Khmer), presentation at research workshop on the Role of Vocational Training in Economic Development in Cambodia, 25 January 2013, Phnom Penh

Hing, V., Khieng S., Lun P., Saing C. & L. Strange (2012), "Introduction: Cambodia Outlook—
An Overview", in *Annual Development Review 2011-12* (Phnom Penh: Cambodia Development Resource Institute)

Huot, C. (2013), "Cambodia: Recent economic developments", presentation at annual meeting of Cambodian Economic Association, 26 January 2013, Phnom Penh

Knight, K. & K. MacLeon (2004), *Integration of teachers' voices into education for all in Cambodia: Teachers' status, social dialogue, and the education sector* (Phnom Penh: PACT-Cambodia)

Mak, N. (2012), "Cambodian higher education: Challenges, opportunities and future directions", presentation at policy roundtable on Higher Education and Vocational Training in Cambodia, 30 August 2012, Phnom Penh

MoEYS & Education Sector Working Group (2005), "Review of the education sector-wide approach in Cambodia", seminar report, 13-15 June 2005, Sunway Hotel, Phnom Penh

National Institute of Statistics (NIS) (2008), *General population census of Cambodia 2008* (Phnom Penh: Ministry of Planning)

National Institute of Statistics (NIS) (2010), *Labour force survey 2007* (Phnom Penh: Ministry of Planning)

Pich, S. (2008), "Responding to changing labour market needs", presentation at Outlook Conference, 28 February 2008, Phnom Penh Hotel, Phnom Penh

Sloper, D. (ed.) (1999), *Higher education in Cambodia: The social and educational context for reconstruction* (Bangkok: UNESCO)

Tong, K. & S. Madhur (2013), "Economic Outlook and Development Challenges", in *Annual Development Review 2012-13*. (Phnom Penh: Cambodia Development Resource Institute)

Un, L. (2012), "A comparative study of education and development in Cambodia and Uganda from their civil wars to the present", Ph.D. thesis (University of Amsterdam)

World Bank (2011), *The Skills to Match Cambodia's Aspirations* (Phnom Penh: World Bank)

World Bank (2012), *Cambodia's economic monitor update (July 2012)* (Phnom Penh: World Bank)


## អំពីវេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា

វេទិកាសិក្សាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា (DRF) បានកកើតឡើងក្រោយពេលដែល មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) រៀបចំវេទិកាស្ថាប័នដៃគូទាំងអស់មួយ នៅខែកញ្ញា ឆ្នាំ2007។

ទស្សនៈវិស័យរបស់ DRF គឺលើកកម្ពស់សហគមន៍ស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជាឲ្យមានគុណភាពខ្ពស់ និងប្រកបដោយវិជ្ជាជីវៈ ព្រមទាំងមានគោលបំណងទ្រទ្រង់ និងពង្រឹងសមត្ថភាពរបស់សហគមន៍ស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា។

ដៃគូក្នុង DRF មាន វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI), សមាគមសេដ្ឋកិច្ចកម្ពុជា (CEA), វិទ្យាស្ថានសិក្សាស្រាវជ្រាវ និង បណ្តុះបណ្តាល (LI), វិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH), សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA), សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP), ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC), និង មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC)។

ក្នុង DRF ដំណាក់កាលទី២ ដោយបានទទួលជំនួយហិរញ្ញវត្ថុពី IDRC ដៃគូទាំងអស់ធ្វើការយ៉ាងសកម្ម ដើម្បីកសាងវប្បធម៌ស្រាវជ្រាវ និងសមត្ថភាពស្រាវជ្រាវ ព្រមទាំងចែករំលែកចំណេះដឹងគ្នាទៅវិញទៅមកតាមរយៈ សិក្ខាសាលា កិច្ចប្រជុំតុមូល ការបណ្តុះបណ្តាល និងពិភាក្សាតាមអ៊ីនធឺណែត (www.drfcambodia.net) ក្រោម ៦ ប្រធានបទ៖ កំណើនសម្រាប់គ្រប់គ្នា, អភិបាលកិច្ចធនធានធម្មជាតិ, គោលនយោបាយសង្គមកិច្ចស្តីពីការអប់រំ, គោលនយោបាយសង្គមកិច្ចស្តីពីសុខាភិបាល, ការអភិវឌ្ឍកសិកម្ម, និង ប្រទេសកម្ពុជានិងតំបន់ជុំវិញ។

## ក្នុងភាពជាដៃគូនៃ

សមាគមសេដ្ឋកិច្ចកម្ពុជា
CAMBODIAN ECONOMIC ASSOCIATION

THE LEARNING INSTITUTE
People and Natural Resources

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
Supreme National Economic Council

IDRC | CRDI


**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ 56 ផ្លូវ 315, ខណ្ឌទួលគោក ✉ ប្រអប់សំបុត្រលេខ 622, ភ្នំពេញ កម្ពុជា

☎ (855 23) 881 384/881 701/881 916/883 603 🖷 (855 23) 880 734

អ៊ីមែល: cdri@cdri.org.kh, គេហទំព័រ: www.cdri.org.kh